ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

ថ្ងៃចន្ទ ១ រោចខែ អាស្វាឡ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ ឧសា ឆ្នាំ ២០១៩

សេចក្តីជូនដំណឹង
ស្តីពីការហាមឃាត់ ការលក់ ឬចែកចាយ ឱសថឈ្មោះ GOLD VIGRA គ្មានបញ្ជិកា
កំពុងផ្សព្វផ្សាយតាមបណ្តាញសង្គម FACEBOOK គ្មានច្បាប់ពីក្រសួងសុខាភិបាល

ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមជម្រាបជូនដល់សាធារណជនទាំងអស់ឱ្យបានជ្រាបថា៖ យោងតាមការពិនិត្យឃើញលើបណ្តាញសង្គមហ្វេសប៊ុក (Facebook) រៀងរាល់ថ្ងៃ មានគណនីឈ្មោះ **Strongest pill** កំពុងផ្សព្វផ្សាយ ឱសថឈ្មោះ GOLD VIGRA គ្មានបញ្ជិកា និងគ្មានច្បាប់ពីក្រសួងសុខាភិបាលឡើយ។ ឱសថឈ្មោះ GOLD VIGRA ជាប្រភេទឱសថផ្សំពីសារធាតុគីមីឈ្មោះ Sildenafil Citrate ដែលជួយបង្កើនតណ្ហាផ្ទូវភេទបុរស ប៉ុន្តែវាប៉ះពាល់ដល់សុខភាព ឬឈានដល់បាត់បង់អាយុជីវិត (ដោយសារការគាំងបេះដូង) របស់អ្នកប្រើប្រាស់។

ក្រសួងសុខាភិបាល សូមជូនដំណឹងដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ឈប់ជឿការផ្សព្វផ្សាយ ឃោសនាភូតកុហកបោកប្រាស់តាមបណ្តាញសង្គមហ្វេសប៊ុកដោយគ្មានមូលដ្ឋានវិទ្យាសាស្ត្រត្រឹមត្រូវរបស់គណនីខាងលើ និងឈប់ប្រើប្រាស់ ឱសថឈ្មោះ GOLD VIGRA គ្មានបញ្ជិកានេះបន្តទៀត ហើយក្រសួងសុខាភិបាលតម្រូវឱ្យម្ចាស់គណនីខាងលើត្រូវបញ្ឈប់ការនាំចូល ផ្សព្វផ្សាយ លក់ ឬចែកចាយ ឱសថឈ្មោះ GOLD VIGRA គ្មានបញ្ជិកានេះជាបន្ទាន់ ។

ក្រសួងសុខាភិបាល នឹងមានវិធានការតឹងរ៉ឹងទៅតាមផ្ទូវច្បាប់ចំពោះម្ចាស់គណនីខាងលើដែលនាំចូល ផ្សព្វផ្សាយ លក់ ឬចែកចាយ ឱសថឈ្មោះ GOLD VIGRA គ្មានបញ្ជិកានេះទៅតាមច្បាប់ស្តីពីការគ្រប់គ្រងឱសថ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងឱសថជាធរមាន។

ក្នុងករណីបងប្អូនប្រជាពលរដ្ឋបានជួបប្រទះឃើញជនណាកំពុងលក់ ឬចែកចាយ ឱសថឈ្មោះ GOLD VIGRA គ្មានបញ្ជិកានេះ សូមបងប្អូនប្រញាប់ផ្តល់ព័ត៌មាន ឬត្រូវការព័ត៌មានបន្ថែមពីនាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង សូមទំនាក់ទំនងតាម រយៈលេខទូរស័ព្ទ៖ **០១១ ៥៧៦ ៧៨៧, ០១២ ៩៨៣ ៣៣៦, ០១២ ៨៩២ ០២២, ០១៧ ៦០៦ ៦៧០, ០១៧ ៨៦៦ ៧៦០។**

សូមភ្ជាប់មកជាមួយនូវរូបភាពគណនី និងឱសថបំប៉នផ្ទូវភេទបុរសឈ្មោះ GOLD VIGRA គ្មានបញ្ជិកា។

ទីស្តីការក្រសួងសុខាភិបាល ដីឡូត៌លេខ ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៦ ៩០៩

ឱសថឈ្មោះ GOLD VIGRA ត្មានបញ្ជិកា

ហាមលក់ ហាមទិញ ហាមប្រើប្រាស់
ប៉ះពាល់ដល់សុខភាព ហូតដល់បាត់បង់អាយុជីវិត

ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ រិចីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៦ ៩០៩

រូបភាពគណនី និងឱសថឈ្មោះ GOLD VIGRA
ត្មានបញ្ជិកា

Strongest pill

Oct 4 at 6:17 AM •

មិនបានយូរ ឆាប់ចេញ ត្មានអារម្មណ៍ មិន
កម្រើក លែងជាបញ្ហាទៀតហើយ
វីយ៉ាហ្ត្រា 3000mg អាចដោះស្រាយបញ្ហា
ខាងលើបានយ៉ាងងាយបំផុត ធានាថាត្រឹមតែ
កន្លះគ្រាប់ ទ្បើងរឹងភ្ល... See More

អត្ថន័យផ្សព្វផ្សាយតាមគណនីនេះ គូតកុហក ឡោកប្រាស់
និងបំផ្លើសហួសពីការពិតត្មានមូលដ្ឋានចិត្សាសាស្ត្រត្រឹមត្រូច

ទីស្តីការក្រសួងសុខាភិបាល ដីឡូត៏លេខ ៨០ រិបីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៦ ៩០៩